# ពុទ្ធិកសមាគមខ្មែរ,ឥង្ក.

The Cambodian Buddhist Society, Inc.

13800 New Hampshire Avenue, Silver Spring, MD 20904

Tel: (301) 622-6544


## សេចក្តីអំពាវនាវសុំឲ្យចូលជាសមាជិក
## និងបង់វិភាគទានប្រចាំឆ្នាំ

ជារៀងរាល់ឆ្នាំ នៅដើមខែនៃឆ្នាំនីមួយ ៗ ក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែរ, ឥង្ក. តែងតែរំលឹកដល់សមាជិកនៃពុទ្ធិកសមាគម ដើម្បីសូមមេត្តាបង់វិភាគទានប្រចាំឆ្នាំ ។

- បើសិនជាសមាជិកណាបានបង់ហើយ សូមមេត្តាបំភ្លេចនូវលិខិតនេះផង ដែលត្រូវផ្ញើទៅគ្រប់គ្នា ។ ក្រុមអភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវិភាគទានដ៏ថ្លៃថ្លានេះ ។
- បើសិនជាសមាជិកណាមិនច្បាស់ថាបង់វិភាគទានហើយឬនៅ អាចបង់ក្នុងពេលនេះក៏បាន ពីព្រោះវិភាគទានដែលបង់នោះនឹងបន្តសមាជិកភាពពីថ្ងៃខែដែលបានបង់ហើយ ។
- បើសិនជាសមាជិកណាមិនទាន់បានបង់វិភាគទាននៅឡើយទេ សូមបង់ឲ្យបានរហ័ស ដើម្បីកុំឲ្យភ្លេចទាន់ ។
- បើសិនជាពុទ្ធបរិស័ទណាមិនទាន់បានចូលជាសមាជិកនៅឡើយទេ សូមលោកអ្នកមេត្តាចុះឈ្មោះចូលតាមលិខិតស្នើគ្រចូលជាសមាជិកដោយភ្ជាប់មកជាមួយនឹងការបង់វិភាគទាននេះ។
- សូមពុទ្ធបរិស័ទទាំងអស់មេត្តាជួយផ្សាយអំពីការចូលជាសមាជិកនេះផង ហើយប្រគល់លិខិតដែលភ្ជាប់មកជាមួយនេះដល់លោកអ្នកដែលមិនទាន់បានចូលជាសមាជិកនៅឡើយ ។

ការចូលជាសមាជិកនៃពុទ្ធិកសមាគមខ្មែរ ឥង្ក. អាចមានប្រយោជន៍ដល់សហគមន៍ខ្មែរទាំងមូលនៅសហរដ្ឋអាមេរិក ។ ឧទាហរណ៍ ការនិមន្តព្រះសង្ឃមកគង់នៅវត្តពុទ្ធិការាម ត្រូវបង្ហាញចំនួនសមាជិកដល់ក្រសួងអន្តោប្រវេសន៍ ។ ម្យ៉ាងទៀត ជារៀងរាល់ឆ្នាំ អាជ្ញាធរអាមេរិកាំងបានធ្វើជំនួយខាងថវិកាឬខាងសង្គមកិច្ចដល់ជនភាគតិច ។ ដើម្បីឲ្យមានលទ្ធភាពនឹងទទួលជំនួយឬធ្វើឲ្យគេចាប់អារម្មណ៍ លុះត្រាតែអង្គការខ្មែរមានសមាជិកច្រើន ។ ពុទ្ធិកសមាគមខ្មែរបានទទួលពុទ្ធបរិស័ទច្រើនណាស់នៅពេលបុណ្យម្តងៗ ។ ពុទ្ធបរិស័ទទាំងនោះ ជាអ្នកគាំទ្រវត្តមែន ប៉ុន្តែមិនទាន់បានក្លាយជាសមាជិកនៃពុទ្ធិកសមាគមខ្មែរយើងនៅឡើយ ។ បើយើងគិតតាមចំនួនខ្មែរដែលរស់នៅក្នុងសហរដ្ឋអាមេរិក សមាជិកពិតប្រាកដតាមផ្លូវការនៃពុទ្ធិកសមាគមខ្មែរ, ឥង្ក. សព្វថ្ងៃនេះមានចំនួន ស្តួចស្តើងណាស់ មិនអាចធ្វើឲ្យអ្នកណាចាប់អារម្មណ៍បានឡើយ ហើយសំឡេងខ្មែរឥតមានអ្នកណាទទួល ស្គាល់ឡើយ ។ មិនតែប៉ុណ្ណោះសោត វិភាគទានរបស់លោកអ្នកនឹងជួយទ្រទ្រង់ និងជួសជុលវត្តឲ្យបានគង់វង្ស តរៀងទៅ ដើម្បីទុកជាទីសក្ការៈបូជានិងជាទីតាំងវប្បធម៌ខ្មែរ ជាពិសេសក្នុងការសង់ព្រះសក្យមុនីចេតិយ ។

អាស្រ័យហេតុនេះ យើងខ្ញុំជាក្រុមអភិបាល សូមអំពាវនាវម្តងទៀតដល់ពុទ្ធសាសនិកជន សូមចុះឈ្មោះចូលជាសមាជិកឲ្យបានច្រើន ។ វិភាគទានប្រចាំខែ ច្រើនឬតិចឥតមានកំណត់
គឺស្រេចទៅលើលទ្ធភាពនិងសទ្ធាជ្រះថ្លា របស់ពុទ្ធបរិស័ទ ។ ជាមធ្យម ពុទ្ធបរិស័ទបង់ $៦០ ក្នុង ១ ឆ្នាំ ។

ធ្វើនៅវត្តពុទ្ធិការាម ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០

ក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែរ, ឥង្ក.

ពុទ្ធិកសមាគមខ្មែរ,ឥន្ក.
The Cambodian Buddhist Society, Inc.
13800 New Hampshire Avenue, Silver Spring, MD 20904
Tel: (301) 622-6544

# APPEAL FOR MEMBERSHIP AND DUE PAYMENT

Every year at the beginning of the year, the Board of Directors of the Cambodian Buddhist Society, Inc., sends a reminder to its members to pay their dues.

- If any members have paid their dues, please disregard this notice because it is being sent to everyone. The Board of Directors greatly appreciates this valuable contribution.
- If any members are not sure whether they have paid their dues, you can pay your dues now because this payment will extend your membership beyond your last payment.
- If any members have not paid their dues, please pay your dues promptly before you forget.
- If any Buddhists have not yet joined the Cambodian Buddhist Society, Inc., please fill out the attached Membership Application and pay the dues.
- All Buddhists are requested to disseminate this membership drive and furnish the Membership Application to non-members.

Being member of the Cambodian Buddhist Society, Inc., is very important to the Cambodian community as a whole in America. For example, in order to sponsor a Cambodian Buddhist Monk to come to America, Vatt Buddhikarama must indicate the number of its members. In addition, each year, the American authority provides financial assistance or social services to communities of minority groups. To receive the assistance, the communities must show their capability and their large membership.. Even though so many Cambodian Buddhists as supporters come to the Temple during festivals, they are not members of the Cambodian Buddhist Society, Inc. In taking into account of the number of Cambodians living in the United States, the number of members is so small that it will impress nobody and thus, Cambodian voice will not be heard. Furthermore, your contribution will support and help maintain the Temple to make it last as worship place and as a conservatory of Cambodian culture, especially during construction of Sakyamuni Stupa.

Consequently, we, members of the Board of Directors wish to appeal for your generosity to become a member. There are no limits to the membership dues. You can make contribution at any amounts according to your ability and your willingness. On average, the due paid by members is $60 per annum.

Vatt Buddhikarama, December 17, 2010
Board of Directors of
the Cambodian Buddhist Society, Inc.